# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣ ស.ស.រ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបើកតំបន់វិនិច្ឆ័យចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋដែលកំពុងរស់នៅតាមសហគមន៍បណ្តោះអាសន្ន ដែលតាំងទីនៅលើដីឯកជនរបស់រដ្ឋក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបើកតំបន់វិនិច្ឆ័យចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋដែលកំពុងរស់នៅតាមសហគមន៍បណ្តោះអាសន្នដែលតាំងទីនៅលើដីឯកជនរបស់រដ្ឋក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម៖

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ប៉ា សុជាតិវង្ស** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | ប្រធាន |
| ២-ឯកឧត្តម | **ស៊ូ គិរិន្ទ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣-ឯកឧត្តម | **ម៉ឹង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៤-ឯកឧត្តម | **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥-ឯកឧត្តម | **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦-លោកជំទាវ | **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ៧-ឯកឧត្តម | **ថៃ នរៈសត្យា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-ឯកឧត្តម | **គឹម ទូច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩-ឯកឧត្តម | **ឈន សុភាព** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម | **ចាន់ សុខុឌ្ឍ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១-ឯកឧត្តម | **កែវ សុធា** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១២-ឯកឧត្តម | **ម៉ៅ ឡាំង** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣-ឯកឧត្តម | **ស្អួស ប្រាថ្នា** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤- លោកជំទាវ | **យក់ សម្បត្តិ** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងសុខាភិបាល | សមាជិកា |
| ១៥- លោក | **ចាន់ ហ៊ីង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៦-លោក | **ទិន សុខហាន់** | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងដោះស្រាយអធិករ | សមាជិក។ |

**ប្រការ២ ..**

គណៈកម្មការអន្តរក្រសួង ដើម្បីបើកតំបន់វិនិច្ឆ័យចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋដែលកំពុងរស់នៅតាមសហគមន៍បណ្តោះអាសន្នដែលតាំងទីនៅលើដីឯកជនរបស់រដ្ឋក្នុងរាជធានីភ្នំពេញ មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ពិនិត្យទីតាំងប្រជាពលរដ្ឋរស់នៅលើដីឯកជនរបស់រដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋនៅតាមក្រសួង អង្គភាពពាក់ព័ន្ធ ដើម្បីកាត់ចេញពីបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋ សម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ
- បន្ទាប់ពីផ្ទៀងផ្ទាត់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលសុរិយោដីរាជធានីភ្នំពេញ ត្រូវចុះបញ្ជីដីធ្លីផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋតាមការកាន់កាប់ជាក់ស្តែង
- បូកសរុបរបាយការណ៍អំពីលទ្ធផលការងាររបស់គណៈកម្មការអន្តរក្រសួងនេះជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ ..**

សមាជិកនៃគណៈកម្មការអន្តរក្រសួងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

www.pheakdeylaw.com

**ប្រការ៤ ..**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសតាមការចាំបាច់ ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ៥ ..**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់សាលារាជធានីភ្នំពេញសម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com